

Washington State Department of HEALTH

# កុមារនិងយុវជនដែលមាន តម្រូវការសុខភាពពិសេស

www.doh.wa.gov/cyshcn

## ព័ត៌មានអំពីវ៉ាក់សាំងជំងឺ COVID-19 និងព័ត៌មានអំពីវ៉ាក់សាំងជំងឺផ្តាសាយធំ

### ព័ត៌មានសម្រាប់អ្នកថែទាំ

ការចាក់វ៉ាក់សាំងមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ Children and Youth with Special Health Care Needs (CYSHCN, កុមារនិងយុវជនដែលមានតម្រូវការថែទាំសុខភាពពិសេស) ដោយសារពួកគេមានហានិភ័យខ្ពស់ជាងក្នុងការឆ្លងជំងឺ COVID-19 និងផ្តាសាយធំ។ នេះក៏ព្រោះតែពួកគេមានបញ្ហាសុខភាពក្នុងខ្លួនស្រាប់ និងមានការប៉ះពាល់ផ្ទាល់ជាមួយអ្នកផ្តល់សេវាថែទាំសុខភាព។ ពួកគេក៏អាចមានបញ្ហាក្នុងការពាក់ម៉ាស់ លាងសម្អាតដៃ និងរក្សាគម្លាតសុវត្ថិភាពពីអ្នកផ្សេងទៀតផងដែរ។

Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ) និង American Academy of Pediatrics (បណ្ឌិតសភាវេជ្ជសាស្ត្រកុមារអាមេរិក) ណែនាំឱ្យចាក់វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំសម្រាប់អ្នកគ្រប់គ្នាដែលមានអាយុ 6 ខែឡើងទៅ។

COVID–19

- វ៉ាក់សាំងជំងឺ COVID-19 ម៉ាក Pfizer ត្រូវបានណែនាំសម្រាប់មនុស្សអាយុ 6 ខែឡើងទៅ។
- វ៉ាក់សាំងជំងឺ COVID-19 ម៉ាក Moderna ត្រូវបានណែនាំសម្រាប់មនុស្សអាយុ 6 ខែឡើងទៅ។
- វ៉ាក់សាំងជំងឺ COVID-19 ម៉ាក Novavax មានផ្តល់ជូនសម្រាប់មនុស្សអាយុ 12 ឆ្នាំឡើងទៅ។
- វ៉ាក់សាំងទាំងនេះមានសុវត្ថិភាព និងប្រសិទ្ធភាពណាស់ក្នុងការការពារកុមារ និងយុវជនពីជំងឺផ្លូវដង្ហើម។

ផ្តាសាយធំ

- ថ្នាំចាក់៖ សម្រាប់មនុស្សអាយុ 6 ខែដល់ 64 ឆ្នាំ មិនមានការណែនាំថាម៉ាកវ៉ាក់សាំងជំងឺផ្តាសាយធំមួយណាល្អជាងមួយណានោះទេ។ វ៉ាក់សាំងជំងឺផ្តាសាយធំទាំងអស់សម្រាប់ឆ្នាំ 2023-24 ការពារទល់នឹងវីរុសផ្តាសាយធំ 4 ប្រភេទ។ ធាតុផ្សំវ៉ាក់សាំងត្រូវបានអាប់ដេតរៀងរាល់ឆ្នាំ ដើម្បីឱ្យត្រូវនឹងប្រភេទវីរុសដែលឆ្លងរាលដាលថ្មីបំផុត។
- ស្ព្រាយបាញ់ច្រមុះ៖ នេះជាវ៉ាក់សាំងរស់ដែលត្រូវបានកែលក្ខណៈ។ វាត្រូវបានអនុញ្ញាតសម្រាប់មនុស្សអាយុ 2 ឆ្នាំដល់ 49 ឆ្នាំ។ វាមិនត្រូវបានណែនាំសម្រាប់មនុស្សមានផ្ទៃពោះ មនុស្សមានប្រព័ន្ធភាពស៊ាំចុះខ្សោយ មនុស្សវ័យចំណាស់ និងមនុស្សមានរបួសលក្ខណៈវេជ្ជសាស្ត្រមួយចំនួនទេ។
- ដូសកម្រិតខ្ពស់ និងបន្ថែមឱសថជំនួយ៖ បង្កើតបានជាប្រតិកម្មភាពស៊ាំខ្លាំងជាងមុន។ វាត្រូវបានណែនាំសម្រាប់មនុស្សធំអាយុ 65 ឆ្នាំឡើង។

### ហេតុអ្វីកុមារគួរចាក់វ៉ាក់សាំង?

ការចាក់វ៉ាក់សាំងជួយរក្សាសុវត្ថិភាពកុមារ ខណៈពេលនៅសាលារៀន ក៏ដូចជាជាមួយមិត្តភក្តិ និងគ្រួសារ។ កុមារដែលបានចាក់វ៉ាក់សាំងនឹងមិនងាយឈឺធ្ងន់ សម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬស្លាប់នោះទេ ប្រសិនបើពួកគេឆ្លងជំងឺ COVID-19។

- កុមារដែលឆ្លងជំងឺ COVID-19 អាចវិវឌ្ឍទៅជាបញ្ហាសុខភាពរយៈពេលខ្លី និងវែង (ជាភាសាអង់គ្លេស) រួមទាំង "ជំងឺ COVID-19 រយៈពេលវែង"។ បញ្ហាសុខភាពមួយចំនួនដូចជា សហរោគសញ្ញារលាកពហុប្រព័ន្ធ (MIS-C)

(ជាភាសាអង់គ្លេស) អាចមានភាពធ្ងន់ធ្ងរ ហើយធ្វើឱ្យមានការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងស្លាប់ទៀតផង។ ការចាក់វ៉ាក់សាំងគឺជាវិធីដ៏ល្អបំផុតក្នុងការរក្សាសុវត្ថិភាពនិងសុខភាពកុមារ។
- កុមារដែលឆ្លងជំងឺផ្តាសាយធំអាចវិវឌ្ឍទៅជាបញ្ហាសុខភាពរយៈពេលខ្លី និងវែង រួមទាំងបញ្ហាបេះដូង។

ការចាក់វ៉ាក់សាំងគឺជាវិធីដ៏ល្អបំផុតក្នុងការរក្សាសុវត្ថិភាព និងសុខភាពកុមារ។

## CYSHCN អាចមានហានិភ័យខ្ពស់ជាងក្នុងការឈឺធ្ងន់ដោយសារជំងឺ COVID–19 និងផ្តាសាយធំ

កុមារដែលមានតម្រូវការថែទាំសុខភាពពិសេស ឬ[បញ្ហាសុខភាពផ្នែកវេជ្ជសាស្ត្រជាក់លាក់](#) (ជាភាសាអង់គ្លេស) ងាយនឹងឈឺធ្ងន់ ប្រសិនបើពួកគេឆ្លងជំងឺ COVID-19 ឬផ្តាសាយធំ។ ការចាក់វ៉ាក់សាំងគឺជាវិធីដ៏សំខាន់ខ្លាំងក្នុងការការពារកុមារពីជំងឺផ្លូវដង្ហើម។

វិធីមួយទៀតក្នុងការការពារកុមារគឺត្រូវប្រាកដថា អ្នកផ្សេងទៀតក្នុងគ្រួសាររបស់ពួកគេបានចាក់វ៉ាក់សាំង និងដូសជំរុញគ្រប់ចំនួន។ នេះមានន័យថា ប្រការសំខាន់គឺឪពុកម្តាយ និងអ្នកថែទាំក៏ត្រូវចាក់វ៉ាក់សាំងដែរ។

## វ៉ាក់សាំងជំងឺ COVID–19 និងផ្តាសាយធំមានសុវត្ថិភាពសម្រាប់ CYSHCN

កុមារ និងមនុស្សធំដែលមានបញ្ហាសុខភាពស្រាប់អាចចាក់វ៉ាក់សាំងជំងឺ COVID-19 បាន។ មូលហេតុតែមួយគត់ដែលមនុស្សម្នាក់មិនគួរចាក់វ៉ាក់សាំងគឺ ប្រសិនបើបុគ្គលនោះមានបញ្ហាប្រតិកម្មដែលអាចគ្រោះថ្នាក់ដល់ជីវិត (ប្រតិកម្មដែលត្រូវការបំពង់ចាក់ថ្នាំស្វ័យប្រវត្តិ) ជាមួយធាតុផ្សំក្នុងវ៉ាក់សាំងណាមួយ។

- [ធាតុផ្សំវ៉ាក់សាំងជំងឺ COVID-19](#) (ជាភាសាអង់គ្លេស)
- [ធាតុផ្សំវ៉ាក់សាំងជំងឺផ្តាសាយធំ](#) (ជាភាសាអង់គ្លេស)

អត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងគឺមានច្រើនជាងហានិភ័យ។ ពិគ្រោះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពកូនរបស់អ្នក ប្រសិនបើអ្នកមានសំណួរ ឬក្តីបារម្ភអំពីវ៉ាក់សាំង។

## ផលប៉ះពាល់

ហានិភ័យសុខភាពនៃការឆ្លងជំងឺ COVID-19 ឬផ្តាសាយធំគឺខ្ពស់ខ្លាំងជាងហានិភ័យនៃផលប៉ះពាល់របស់វ៉ាក់សាំង។ វាជារឿងធម្មតាដែលកុមារមានអារម្មណ៍ថាមានផលប៉ះពាល់ខ្លះៗ បន្ទាប់ពីចាក់វ៉ាក់សាំង។ ផលប៉ះពាល់ទូទៅបំផុតគឺ៖

- ឈឺដៃ
- ឈឺសាច់ដុំ
- អស់កម្លាំង
- ឈឺក្បាល
- គ្រុនក្តៅ
- ព្រឺរងា

សាកសួរអ្នកផ្តល់សេវាថែទាំសុខភាពកូនរបស់អ្នកអំពីរបៀបធ្វើឱ្យកូនរបស់អ្នកកាន់តែមានផាសុកភាព បើគាត់មានផលប៉ះពាល់។ អ្នកក៏អាចធ្វើឱ្យគាត់មានផាសុកភាពដោយសកម្មភាពស្ងាត់ៗផងដែរ។ ផលប៉ះពាល់ភាគច្រើនបាត់ទៅវិញក្នុងរយៈពេល 1 ទៅ 2 ថ្ងៃ។

ប្រសិនបើកូនរបស់អ្នកមានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរជាមួយវ៉ាក់សាំងផ្សេងទៀត គាត់ក៏នៅតែអាចចាក់វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំបានដែរ។ អ្នកផ្តល់សេវាថែទាំសុខភាពនឹងប្រាប់ឱ្យគាត់រង់ចាំប្រហែល 30 នាទីក្រោយពីចាក់រួច ដើម្បីមើលក្រែងមានប្រតិកម្មភ្លាមៗណាមួយ។

ហានិភ័យដែលអាចមានប្រតិកម្មធ្ងន់ធ្ងរជាមួយវ៉ាក់សាំងទាំងនេះមានកម្រិតទាបណាស់។ ហានិភ័យក្នុងការវិវឌ្ឍទៅជារោគសញ្ញាធ្ងន់ធ្ងរក្រោយពីឆ្លងជំងឺផ្លូវដង្ហើមគឺខ្ពស់ខ្លាំងជាងហានិភ័យក្នុងការបង្កផលប៉ះពាល់ធ្ងន់ធ្ងរក្រោយចាក់វ៉ាក់សាំង។ ស្វែងយល់បន្ថែមអំពីផលប៉ះពាល់ធ្ងន់ធ្ងរដែលអាចមានពីការចាក់វ៉ាក់សាំងជំងឺ COVID-19

នៅទីនេះ៖

[វ៉ាក់សាំងជំងឺ COVID-19](#) (ជាភាសាអង់គ្លេស)

[វ៉ាក់សាំងជំងឺផ្តាសាយធំ](#) (ជាភាសាអង់គ្លេស)

ប្រសិនបើអ្នកមានការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រក្រោយចាក់វ៉ាក់សាំងជំងឺ COVID-19 សូមទូរសព្ទទៅលេខ 9-1-1 ជាបន្ទាន់។

## តើខ្ញុំអាចនាំកូនខ្ញុំទៅចាក់វ៉ាក់សាំងតាមវិធីណា?

សាកសួរគ្រូពេទ្យកុមាររបស់អ្នកថាតើពួកគេផ្តល់វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំឬអត់។ បើអត់ទេ អ្នកអាចប្រើទំព័រស្វែងរកទីតាំងចាក់វ៉ាក់សាំង (ជាភាសាអង់គ្លេស) របស់យើង។

## ការស្នើសុំការសម្របសម្រួល

នៅពេលអ្នកធ្វើការណាត់ជួប ឬទៅដល់ទីតាំងចាក់វ៉ាក់សាំង សូមប្រាប់បុគ្គលិកឱ្យដឹង ប្រសិនបើកូនរបស់អ្នកត្រូវការជំនួយបន្ថែម។ ឧទាហរណ៍ ប្រហែលជាគាត់មិនអាចពាក់ម៉ាស់ ឬអង្គុយរង់ចាំក្រោយពេលចាក់រួច។ ប្រហែលជាបន្ទប់មានសំឡេងរំខាន និងពន្លឺភ្លឺប៉ះពាល់ដល់គាត់។ អ្នកអាចស្នើសុំការសម្របសម្រួលដូចជា៖

- ដើរចុះឡើងក្រោយពេលចាក់ ជំនួសឱ្យការអង្គុយ។
- ស្នើឱ្យអ្នកផ្តល់សេវាចាក់វ៉ាក់សាំងកូនរបស់អ្នកក្នុងរថយន្តរបស់អ្នក។
- ស្នើឱ្យដៃគូដែលកូនរបស់អ្នកចូលចិត្តនៅក្បែរគាត់ អំឡុងពេលណាត់ជួប។
- ស្នើឱ្យចាក់វ៉ាក់សាំងកូនរបស់អ្នកក្នុងបន្ទប់ស្ងាត់ ឆ្ងាយពីហ្វូងមនុស្ស។

## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមទៀតបាននៅកន្លែងណា?

ដើម្បីទទួលបានព័ត៌មានថ្មីៗបំផុតអំពីការចាក់វ៉ាក់សាំងយុវជន៖

សម្រាប់ជំងឺ COVID-19 សូមចូលមើល VaccinateWA.org/Kids

សម្រាប់ជំងឺផ្តាសាយធំ សូមចូលមើល Flufreewa.org (ជាភាសាអង់គ្លេស)

ធនធានផ្សេងទៀត៖

- ការណែនាំពី American Academy of Pediatrics អំពីការថែទាំ CYSHCN អំឡុងពេលឆ្លងរាលដាលជាសកល (ជាភាសាអង់គ្លេស)។
- ព័ត៌មាន និងជំនួយទាក់ទងនឹងជំងឺផ្តាសាយធំរបស់ CDC សម្រាប់មនុស្សមានពិការភាព (ជាភាសាអង់គ្លេស)។
- ធនធានទាក់ទងនឹងជំងឺ COVID-19 សម្រាប់ CYSHCN (ជាភាសាអង់គ្លេស) ពី Lucile Packard Foundation។
- ព័ត៌មាន និងជំនួយទាក់ទងនឹងជំងឺ COVID-19 (ជាភាសាអង់គ្លេស) ពី Informing Families (ជូនដំណឹងគ្រួសារ) ។
- ការណែនាំអំពីជំងឺផ្តាសាយធំសម្រាប់មាតាបិតា (ជាភាសាអង់គ្លេស) ដើម្បីជួយការពារ និងថែទាំកូនៗពី/ដែលមានជំងឺផ្តាសាយធំ។
- ប័ណ្ណទំនាក់ទំនងវ៉ាក់សាំងជំងឺ COVID-19 (ជាភាសាអង់គ្លេស) របស់ Department of Health និងរឿងរ៉ាវសង្ខេបរបស់ Center for Dignity in Healthcare for People with Disabilities (មជ្ឈមណ្ឌលដើម្បីសេចក្តីថ្លៃថ្នូរក្នុងការថែទាំសុខភាពសម្រាប់មនុស្សមានពិការភាព) អាចជួយធ្វើទំនាក់ទំនងជាមួយកុមារ ឬយុវជនអំពីវ៉ាក់សាំង។

- ខ្សែទូរសព្ទ (360-947-3330) របស់ BLIND COVID Access អនុញ្ញាតឱ្យជនពិការភ្នែក និងខ្សោយភ្នែកសួរសំណួរអំពីលទ្ធភាពទទួលបានធនធានទាក់ទងនឹងជំងឺ COVID-19។ BLINDCOVID.com (ជាភាសាអង់គ្លេស) នឹងរៀបចំធនធានបន្ថែម និងការធ្វើទំនាក់ទំនងអំពីការធ្វើតេស្តលើការចាក់វ៉ាក់សាំង ទីតាំងវ៉ាក់សាំង និងរបៀបរស់នៅប្រចាំថ្ងៃក្នុងពេលឆ្លងរាលដាលជាសកល។
- សម្រាប់សំណួរជាក់លាក់អំពី CYSHCN សូមផ្ញើអ៊ីមែលទៅ cyshcn@doh.wa.gov។

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។